សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## កិច្ចការស្រាវជ្រាវ

# ការប្រៀបធៀបអង្គការនីតិបញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃ

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**
ឆ្នាំចូលសិក្សា ២០១៣

ជំនាញ **នីតិឯកជន** ជំនាន់ទី១០
ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៣

**រក្សាសិទ្ធិដោយ** Khmer Famous

# សេចក្តីផ្តើម

នៅតាមបណ្តាប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ ទាក់ទងទៅនឹងការបែងចែកអំណាចដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវបានគេកត់សម្គាល់ឃើញថារមែងតែងតែមានវត្តមានអំណាចធំៗ ៣ គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ជាគោលការណ៍ អំណាចនីតិបញ្ញត្តិ ត្រូវបានប្រគល់ឲ្យទៅអង្គការនីតិបញ្ញត្តិតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការតាក់តែងច្បាប់។ ចំណែកឯ អំណាចនីតិប្រតិបត្តិ ត្រូវបានប្រគល់ឲ្យទៅអង្គការនីតិប្រតិបត្តិ ដែលសំដៅទៅរដ្ឋាភិបាលនោះឯង និងចុងក្រោយគឺអំណាចតុលាការ គឺប្រគល់ទៅឲ្យគណៈយុត្តាធិការ ដែលជាស្ថាប័នឯករាជ្យ មិនចំណុះឲ្យស្ថាប័នណាផ្សេងឡើយ។ អំណាចទាំងបី ខាងលើនេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាគឺជាអំណាចរបស់ស្ថាប័នកំពូលដែលមានសិទ្ធិក្នុងការរៀបចំ ដឹកនាំ គ្រប់គ្រងដំណើរការវិវត្តន៍ទៅរបស់ប្រទេសនីមួយ។ យ៉ាងណាមិញ បើទោះបីទ្រឹស្តីនៃគោលការណ៍លទ្ធិប្រជាធិបតេយ្យ ដែលតម្រូវឲ្យប្រទេសនីមួយៗដែលអនុវត្តរបបនេះ ត្រូវតែមានជាចាំបាច់នូវ អង្គការទាំងបីខាងលើ ប៉ុន្តែដំណើរការប្រព្រឹត្តទៅមួយចំនួន និងការបែងចែករចនាសម្ព័ន្ធ មានចរឹកលក្ខណៈមិនដូចគ្នាទាំងស្រុងឡើយ។ ជាក់ស្តែង ករណីព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដែលជាប្រទេសស្ថិតនៅក្នុងប៉ែកអាស៊ីអាគ្នេយ៍រួមគ្នា និងជាប្រទេសជិតខាងគ្នា ដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យដូចគ្នា ប៉ុន្តែបើគេពិនិត្យមើលទៅលើ រូបភាពនៃការបែងចែកអំណាចកំពូល ជាពិសេសគឺ អង្គការនីតិបញ្ញត្តិ មានភាពខុសគ្នាពីប្រទេសកម្ពុជាមួយចំនួន។ ដោយសារតែ យើងខ្ញុំយល់ឃើញអំពីសារៈសំខាន់នៃការយល់ដឹងទៅលើអង្គការនីតិបញ្ញត្តិ រួមជាមួយនឹងភាពខុសប្លែកគ្នារវាងប្រទេសទាំងពីរ ទើបធ្វើការសម្រេចចងក្រងនូវកិច្ចការស្រាវជ្រាវតូចមួយ ដែលសិក្សាទៅលើ ការប្រៀបធៀបអង្គការនីតិបញ្ញត្តិរបស់ប្រទេសកម្ពុជានិងប្រទេសថៃ។ សម្រាប់ខ្លឹមសារលម្អិត យើងខ្ញុំនឹងធ្វើការបង្ហាញជាបន្តបន្ទាប់នៅផ្នែកខាងក្រោម។

# ផ្នែកទី១
# អង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា

ក្រោយពីការបោះឆ្នោតឆ្នាំ ១៩៩៣ មក ព្រះរាជាណាចក្រកម្ពុជាទទួលបានសភាមួយដែលមានឈ្មោះថា សភាធម្មនុញ្ញ មានភារកិច្ច តាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញ។ នៅក្រោយពេលរដ្ឋធម្មនុញ្ញបានអនុម័តរួចហើយ និង ត្រូវបានប្រកាសអោយប្រើដោយព្រះមហាក្សត្រ នៅពេលនោះសភាធម្មនុញ្ញក៏បានក្លាយទៅជា សភាជាតិ។

អំណាចរបស់ប្រទេសនេះ ត្រូវបានចែកចេញជា ៣ គឺ អំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ស្ថាប័នកំពូលដែលមានសិទ្ធិក្នុងការតាក់តែងច្បាប់ ត្រូវបានប្រគល់ឲ្យទៅ អង្គការនីតិបញ្ញត្តិតែមួយគត់។ អង្គការនីតិបញ្ញត្តិ សំដៅទៅលើស្ថាប័នសភា។ ស្ថាប័នសភានៅកម្ពុជា ត្រូវបានចែកចេញជា ២ គឺ រដ្ឋសភា/ សភាតំណាងរាស្ត្រ និងព្រឹទ្ធសភា។

## ក/ អំពីរដ្ឋសភា

ដំណោះស្រាយវិវាទនៅកម្ពុជា តាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ បានកំណត់ឲ្យមានការបោះឆ្នោត ដើម្បីកសាងនីតិរដ្ឋ និងបង្កើតស្ថាប័នគ្រប់គ្រងប្រទេស។ ក្នុងស្មារតីនេះ ការបោះឆ្នោតលើកទី១ បានប្រព្រឹត្តទៅនៅថ្ងៃទី ២៣ ឧសភា ១៩៩៣ នៅទូទាំងប្រទេស ដើម្បីជ្រើសរើសសភាធម្មនុញ្ញមួយរូប។ ក្នុងឱកាសនោះ មានគណបក្សចំនួន ១៩ បានចូលរួមប្រកួតប្រជែង សម្រាប់មណ្ឌល ២១ ក្នុងគោលដៅជ្រើសរើសតំណាងរាស្ត្រ ១២០រូប។ រដ្ឋធម្មនុញ្ញ ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ កញ្ញា ឆ្នាំ១៩៩៣។ ក្នុងពេលនោះដែរ សភាធម្មនុញ្ញក៏បានក្លាយទៅជាសភាជាតិ សម្រាប់អាណត្តិទី១ រយៈពេល ៥ឆ្នាំ (១៩៩៣ ដល់ ១៩៩៨)។ នាពេលនោះ រដ្ឋាភិបាលចម្រុះមួយត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងប្រទេសសម្រាប់រយៈពេល ៥ឆ្នាំតាមរូបមន្ត ៤៥%+៤៥%+១០% និងមានសហនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីសម្រាប់ក្រសួងការពារជាតិ និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ មកទល់នឹងបច្ចុប្បន្ន រដ្ឋសភានៃនីតិកាល ទី៥ ត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោត នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។

រដ្ឋសភា ជាអង្គការកំពូលតំណាងជាន់ខ្ពស់របស់ប្រជាពលរដ្ឋ និងជាអង្គការដែលមានអំណាចនីតិបញ្ញតិ ហើយមានសមាជិក ១២៣ រូប ដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសាកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ រដ្ឋសភា មានប្រធានម្នាក់ និងអនុប្រធានពីរនាក់។ ការប្រជុំរបស់រដ្ឋសភាត្រូវប្រព្រឹត្តទៅជាសាធារណៈ ប៉ុន្តែគេអាចប្រជុំជាសម្ងាត់បាន ប្រសិនបើមានការស្នើសុំពី

សមាជិករដ្ឋសភា ១/១០ យ៉ាងតិច ឬ ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី។ ការប្រជុំនេះ អាចយកជាការបាន លុះត្រាតែមានកូរ៉ុម ៧/១០ នៃសមាជិកសភាទាំងមូល។

### ក.១. អំពីសមាជិករដ្ឋសភា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧៦ បានចែងថា 'រដ្ឋសភាមានសមាជិកយ៉ាងតិច ១២០រូប។តំណាងរាស្ត្រត្រូវជ្រើសរើសដោយការបោះឆ្នោតជាសាកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ តំណាងរាស្ត្រអាចឈរឈ្មោះឲ្យគេបោះឆ្នោតសារជាថ្មីបាន។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធបោះឆ្នោតមានអាយុយ៉ាងតិច ២៥ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត។ អង្គការរៀបចំបែបបទបោះឆ្នោត និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត។' តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួនទេ។ អាណត្តិបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ។

### ក.២. ភារកិច្ចរបស់រដ្ឋសភា

រដ្ឋសភាជាអង្គការនីតិបញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ តាមសំណើររបស់សមាជិករដ្ឋសភា ១/១០ យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរៈជនណាម្នាក់អោយមកបំភ្លឺក្នុងរដ្ឋសភាបាន ។ រដ្ឋសភាជាអំណាចនីតិបញ្ញត្តិដែលមានសិទ្ធិតាក់តែងច្បាប់ អនុម័តថវិកាជាតិ ផែនការរដ្ឋអោយរដ្ឋខ្ចីប្រាក់ពីគេ និងអោយរដ្ឋឲ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ ការបង្កើតកែប្រែ និងលុបចោលពន្ធដារ ព្រមទាំងភារកិច្ច មួយចំនួនទៀតដូចជា ៖

- រដ្ឋសភាជាអ្នកផ្តល់សេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល
- រដ្ឋសភាអនុម័តច្បាប់ស្តីពី ការលើកលែងទោសជាទូទៅ
- រដ្ឋសភាអនុម័តយល់ព្រម ឬ លុបចោលនូវសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិ
- រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម
- រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល
- តំណាងរាស្ត្រមានសិទ្ធិធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។
- រដ្ឋសភាមានសិទ្ធិទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬ ទម្លាក់រដ្ឋាភិបាលចេញពីតំណែងតាមសម្លេង ២/៣ នៃសមាជិករដ្ឋសភាទាំងមូល ដោយអនុម័តញ្ញត្តិបន្ទោស។
  យោងតាមមាត្រា៩០ថ្មី នៃរដ្ឋធម្មនុញ្ញ បានចែងថា ៖

### ក.៣. អាណត្តិរបស់រដ្ឋសភា

រដ្ឋសភា មានអាណត្តិ ៥ឆ្នាំ។ នីតិកាលរបស់រដ្ឋសភា ត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់ដំណែង។ រដ្ឋសភា មិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ។ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានទម្លាក់ពីរដងក្នុងរយៈពេល ១២ខែ។

### ក.៤. វិសមិតភាព និងអភ័យឯកសិទ្ធិសភា

តំណាងរាស្ត្រ មិនអាចបំពេញមុខងារជាសមាជិករដ្ឋសភាផង ជាសមាជិកព្រឹទ្ធសភាផង ជាអ្នករាជការកាន់កាប់ដំណែងនៅក្នុងពេលតែមួយបានទេ មានន័យថាអាណត្តិរបស់សមាជិករដ្ឋសភាមានវិសមិតភាពជាមួយ ការបំពេញមុខងារសាធារណៈ និងមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរដ្ឋាភិបាល។ ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា ដោយគ្មានមុខដំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មាការផ្សេងៗទៀតនៃរដ្ឋសភា។

ចំណែកឯអភ័យឯកសិទ្ធិសភា ជាការការពារអំពើគតិយុត្តដែលរដ្ឋាភិបាល ឬ បុគ្គលណាមួយប្រឆាំងនឹងសមាជិកសភា។ ដើម្បីឲ្យសមាជិកសភាបំពេញមុខការជាតំណាងឲ្យប្រជាពលរដ្ឋ និងការពារសមាជិកសភា រដ្ឋធម្មនុញ្ញបានចែងអំពីអភ័យឯកសិទ្ធសភា។ តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួ សមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ ពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ ដើម្បីសម្រេច។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើនពីរភាគបួននៃសមាជិក រដ្ឋសភាទាំងមូល។

## ខ/ អំពីព្រឹទ្ធសភា

ក្រោយពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី២ ឆ្នាំ១៩៩៨មក ប្រទេសបានជួបនឹងវិបត្តិនយោបាយម្តងទៀត។ នៅពេលនោះព្រះមហាក្សត្របានកោះហៅឥស្សរៈ

ជនជាន់ខ្ពស់ ជាពិសេសថ្នាក់ដឹកនាំគណបក្សនយោបាយធំៗទាំងពីរដែលបានជាប់ឆ្នោតមកសម្រុះសម្រួល ដើម្បីបង្កើតរដ្ឋាភិបាលចម្រុះមួយដែលមានពីរគណបក្សគឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ីនប៉ិច ហើយក៏មានលក្ខខណ្ឌឲ្យបង្កើតស្ថាប័នព្រឹទ្ធសភានេះឡើង។ ខណៈពេលនោះ រដ្ឋសភាអាណត្តិទី២ ក៏បានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី២ នូវមាត្រាមួយចំនួន និងមាត្រាទាំងឡាយនៃជំពូក៨ ដល់ជំពូក១៤ ដែលបានផ្តល់សច្ចានុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩ ដែលមាននិយាយអំពីព្រឹទ្ធសភា។ ពេលនោះហើយដែលព្រឹទ្ធសភាត្រូវបានបង្កើតឡើង និងចាប់ដំណើរការនីតិកាលដំបូងរបស់ខ្លួននៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។

ព្រឹទ្ធសភា មានប្រធានមួយរូប និងអនុប្រធានពីររូប ហើយមានចំនួនសមាជិកស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ដែលសមាជិកទាំងនេះខ្លះត្រូវចាត់តាំង និងត្រូវជ្រើសតាំងដោយអសកលខ្លះ។ សមាជិកព្រឹទ្ធសភាម្នាក់ៗ មានសិទ្ធិបញ្ចេញមតិយោបល់របស់ខ្លួនដោយសេរីនៅក្នុងសម័យប្រជុំរបស់ព្រឹទ្ធសភា។ ព្រឹទ្ធសភា មានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរដ្ឋាភិបាល។

### ខ.១. អំពីសមាជិកព្រឹទ្ធសភា

អ្នកដែលមានសិទ្ធឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត។ សមាជិកចំនួន ២រូប ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ និង២រូប ទៀតត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប រីឯសមាជិកព្រឹទ្ធសភាដទៃទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។

### ខ.២. ភារកិច្ចរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភា មានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និង រដ្ឋាភិបាល។ ព្រឹទ្ធសភាពិនិត្យ ហើយឲ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងបញ្ហាទាំងពួងដែលរដ្ឋសភាដាក់ឲ្យពិនិត្យ។ បើជាការប្រញាប់រយៈពេលនេះត្រូវបន្ថយមកត្រឹម៥ថ្ងៃ។ បើព្រឹទ្ធសភាបានឲ្យយោបល់យល់ព្រម ឬពុំបានឲ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះនឹងត្រូវបានយកទៅប្រកាសឲ្យប្រើ។ បើព្រឹទ្ធសភាសុំអោយកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភាត្រូវពិនិត្យ

និងសម្រេចតែត្រង់បទបញ្ញត្តិ ឬ ចំណុចណាដែលព្រឹទ្ធសភាសុំអោយកែសម្រួលដោយបដិសេធចោលទាំងមូល ឬ ទុកជាបានការខ្លះ។

ការបង្វិលមកវិញរវាងព្រឹទ្ធសភា និងរដ្ឋសភាត្រូវតែធ្វើក្នុងរយៈពេលមួយខែ។ រយៈពេលនេះបន្ថយមកត្រឹម ១០ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកា និងហិរញ្ញវត្ថុ ហើយមកត្រឹមតែ ២ថ្ងៃ បើជាការប្រញាប់។ បើរដ្ឋសភាទុកឲ្យហួសរយៈពេលកំណត់ ឬ សន្យាពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍របស់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមឲ្យស្មើគ្នាដែរ។ បើព្រឹទ្ធសភា បដិសេធសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះជាអាសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទី២ មុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹម ១០ថ្ងៃ បើពិនិត្យថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែ ០៤ថ្ងៃ បើជាការប្រញាប់។ ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ជាលើកទីពីរនេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហរ និងយកតាមមតិភាគច្រើនដាច់ខាត សេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ណាដែលបានសម្រេចដូចខាងលើនេះហើយនោះនឹងត្រូវបានយកប្រកាសអោយប្រើ។

ព្រឹទ្ធសភា បង្កើតគណៈកម្មាការដែលចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានអនុម័តយល់ព្រមដោយសម្លេងភាគច្រើន ពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាកសមាជិកភាពដែលកើតមានឡើងប្រាំមួយខែយ៉ាងតិច មុនចប់នីតិកាលត្រូវចាត់តាំង ត្រូវជ្រើសតាំងចំនួនសមាជិកនោះ តាមលក្ខខណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និងក្នុងច្បាប់ស្តីពីការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

### ខ.៣. អាណត្តិរបស់ព្រឹទ្ធសភា

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់ដំណែង។ ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើររបស់ព្រះមហាក្សត្រ។ ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។ ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំជាប់ជាប្រចាំ។ ព្រឹទ្ធសភាមានសិទ្ធិបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាតិ។ បើព្រឹទ្ធសភាមិនអាចប្រជុំបានទេដោយមូលហេតុចាំបាច់ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។

ខ.៤. វិសមិតភាព និងអភ័យឯកសិទ្ធរបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា។ សមាជិកព្រឹទ្ធសភារូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនសមាជិកសភាណាមួយនៃព្រឹទ្ធសភានឹងអាចធ្វើទៅកើត លុះត្រា តែមានការយល់ព្រមពីព្រឹទ្ធសភា ឬ ពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ ដើម្បីសម្រេច។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល។ ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិអោយផ្អាកតាមមតិភាគច្រើន បីភាគបួននៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

## ផ្នែកទី ២
## អង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រថៃ

សភាថៃ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៣២ ក្រោយពេលដែលរដ្ឋធម្មនុញ្ញដំបូងរបស់ប្រទេសថៃត្រូវបានបង្កើតឡើង និងក្នុងពេលដែលរបបដឹកនាំប្រទេសថៃត្រូវបានផ្លាស់ប្តូរពីរបបរាជានិយមផ្តាច់ការ ទៅជារាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ សភាថៃ ជួបប្រជុំជាលើកទីមួយនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៣២ នា Ananda Samakhom Throw Hall ។ មិនខុសពីព្រះរាជាណាចក្រកម្ពុជា, ប្រទេសថៃក៏ជាទ្វីកសភាដែរ គឺរួមមាន ព្រឹទ្ធសភា និង សភាតំណាង ដែលប្រទេសកម្ពុជា ហៅថា រដ្ឋសភា។

### ក/ អំពីព្រឹទ្ធសភា

ព្រឹទ្ធសភា គឺជាសភាជាន់ខ្ពស់ នៃអង្គការនីតិបញ្ញត្តិ ហើយត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៦។ ព្រឹទ្ធសភាបច្ចុប្បន្នមានសមាជិក ១៥០រូប ដោយក្នុងនោះ ៧៦រូប ត្រូវបានបោះឆ្នោត ១រូប ក្នុងមួយខេត្ត ពីខេត្តចំនួន ៧៥ និង ១រូប ពីតំបន់ប្រជុំជនបាងកក ហើយ ៧៤រូបទៀត ត្រូវបានជ្រើសរើសដោយគណៈកម្មាការជ្រើសរើសព្រឹទ្ធសភា ដែលបានមកពីមន្ត្រីដែលត្រូវបានតែងតាំង និងមន្ត្រីជាប់ឆ្នោតចេញពីវិស័យមួយចំនួនដូចជា ៖ វិស័យអប់រំ វិស័យសាធារណៈ , វិស័យឯកជន...។

ក.១. សមាជិកព្រឹទ្ធសភា

ផ្អែកទៅតាមខ្លឹមសារនៃរដ្ឋធម្មនុញ្ញប្រទេសថៃ ដែលបានរៀបរាប់អំពីព្រឹទ្ធសភា បានកំណត់ថា ដើម្បីអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការក្លាយខ្លួនជាបេក្ខភាពសមាជិកព្រឹទ្ធសភាសម្រាប់ការបោះឆ្នោត និងសម្រាប់ការជ្រើសតាំង ចាំបាច់ត្រូវតែបំពេញនូវលក្ខខណ្ឌ ៨យ៉ាង រួមមាន ៖

- ត្រូវតែមានសញ្ជាតិថៃពីកំណើត
- ត្រូវមានអាយុមិនតិចជាង ៤០ឆ្នាំ គិតត្រឹមថ្ងៃបោះឆ្នោត ឫ កាលបរិច្ឆេទនៃការតែងតាំង។
- ត្រូវតែបានបញ្ចប់ការសិក្សាយ៉ាងតិចត្រឹមថ្នាក់បរិញ្ញាបត្រ
- ចំពោះបេក្ខជនដែលឈរឈ្មោះសម្រាប់ការបោះឆ្នោត ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ៖
    - មានឈ្មោះក្នុងបញ្ជីចុះឈ្មោះនៅ Changwat ទីកន្លែងសម្រាប់ឈរឈ្មោះបោះឆ្នោតក្នុងរយៈពេលមិនតិចជាង ៥ឆ្នាំ ឡើងទៅគិតទៅដល់ថ្ងៃដែលបេក្ខជនត្រូវដាក់ពាក្យសម្រាប់ការបោះឆ្នោត។
    - ត្រូវតែជាបុគ្គលដែលបានកើតនៅ Changwat ទីតាំងដែលត្រូវឈរឈ្មោះឲ្យគេបោះឆ្នោត។
    - ត្រូវតែបានសិក្សានៅវិទ្យាស្ថានអប់រំរបស់ Changwat រយៈពេលមិនតិចជាង ៥ឆ្នាំ។
    - បានបម្រើការជាផ្លូវការនៅ Changwat ក្នុងរយៈពេលជាប់គ្នា ដោយមិនតិចជាង ៥ឆ្នាំ។
- មិនត្រូវជាសហព័ទ្ធ ឫ ជាកូនរបស់សមាជិកសភាតំណាង ឫ អ្នកមានមុខការជាអ្នកនយោបាយ។
- មិនត្រូវជាសមាជិក ឫ បុគ្គលណាមួយ ដែលកាន់កាប់ការងារនៅក្នុងគណបក្សនយោបាយ ឫ ធ្លាប់ជាសមាជិកណាមួយដែលមានតួនាទីក្នុងគណបក្សនយោបាយ ហើយសមាជិកភាពរបស់គាត់ត្រូវបានបញ្ចប់ ឫ លាលែង ដែលមានរយៈពេលមិនច្រើនជាង៥ឆ្នាំ គិតដល់ថ្ងៃដែលគាត់ដាក់ពាក្យធ្វើបេក្ខជន ឫ ថ្ងៃដែលត្រូវតែងតាំង។
- ត្រូវបានដកហូតសិទ្ធិពលរដ្ឋ ដូចមានចែងក្នុងមាត្រា ១០២ នៃរដ្ឋធម្មនុញ្ញ។
- មិនមែនជារដ្ឋមន្ត្រី ឫ បុគ្គលដែលកាន់កាប់ការងារនយោបាយដទៃទៀត។

ក.២. ភារកិច្ចរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភា ត្រូវបំពេញភារកិច្ចចែកចេញជា ២ផ្នែកធំៗ ៖

- ភារកិច្ចដែលត្រូវធ្វើរួមគ្នាជាមួយសភាតំណាង ៖
  - ការតាក់តែងច្បាប់
  - ការត្រួតពិនិត្យលើការតាក់តែងច្បាប់
  - អនុម័តសេចក្តីព្រាងច្បាប់
  - ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ
- អំណាចផ្តាច់មុខ ៖
  - បង្កើត និងតែងតាំងគណៈកម្មាធិការសម្រាប់ត្រួតពិនិត្យ និងស៊ើបអង្កេតលើកិច្ចការងាររបស់ព្រឹទ្ធសភា។
  - អនុម័តសេចក្តីសម្រេចផ្តល់យោបល់ថ្វាយដល់ព្រះមហាក្សត្រ
  - ជាចៅក្រមនៃតុលាការធម្មនុញ្ញរបស់ប្រទេសថៃ
  - ជាសមាជិកគណៈកម្មាការបោះឆ្នោត
  - ជាតំណាងការិយាល័យប្រជាពលរដ្ឋ
  - ជាសមាជិកនៃគណៈកម្មាការប្រឆាំងអំពើពុករលួយ, គណៈកម្មាការសវនកម្មជាតិ (រួមទាំងសវនករទូទៅ) និងគណៈកម្មាការជាតិទទួលបន្ទុកសិទ្ធិមនុស្ស
  - មានអំណាចក្នុងការផ្តល់យោបល់ស្តីពីការតែងតាំងសមាជិកមួយចំនួនរបស់អំណាចតុលាការ និងទីភ្នាក់ងាររបស់រាជរដ្ឋាភិបាលឯករាជ្យនានា។
  - ជ្រើសរើសមន្ត្រីបម្រើការរបស់ខ្លួន
  - មានសិទ្ធិក្នុងការបណ្តេញចេញសមាជិករបស់ខ្លួន
  - កំណត់អំពីវិធាន និងនីតិវិធីនៃដំណើរការស្ថាប័នរបស់ខ្លួន

### ក.៣. អាណត្តិរបស់ព្រឹទ្ធសភា

អាណត្តិរបស់ព្រឹទ្ធសភាគឺមានរយៈពេល ៦ឆ្នាំ និងមិនអាចបន្តជាថ្មី និងមិនអាចត្រូវបានរំលាយក្នុងកាលៈទេសៈណាមួយបានឡើយ។ ព្រឹទ្ធសភានឹងត្រូវបានបោះឆ្នោតឡើងវិញដោយអនុលោមទៅតាមព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រដែលត្រូវដាក់ចេញនៅក្នុងអំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផុតកំណត់។

### ក.៤. អភ័យឯកសិទ្ធិសភា

សមាជិកព្រឹទ្ធសភា មានអភ័យឯកសិទ្ធិសភា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ មិនមានសមាជិកព្រឹទ្ធសភាណាមួយត្រូវបាន ចាប់ខ្លួន ឃាត់ខ្លួន ឬ ត្រូវបានកោះហៅដោយដីកាក្នុងគោលដៅនៃការស៊ើបអង្កេត។ ក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ចាំបាច់ត្រូវតែមានការអនុញ្ញាតិពីព្រឹទ្ធសភា។

## ខ/ សភាតំណាង

សភាជាន់ទាបរបស់ព្រះរាជាណាចក្រថៃ ត្រូវបានគេហៅថាជា សភាតំណាង។ សភាតំណាង បានចាប់បដិសន្ធិឡើងនៅឆ្នាំ ១៩៣២។ សភានេះ គឺជាសភាគណបក្សមួយ ហើយក៏ជាសភាដំបូងរបស់អំណាចនីតិបញ្ញត្តិ និងមានអំណាចខ្លាំងជាងព្រឹទ្ធសភា ព្រោះសភានេះ មានអំណាចដកហូតដំណែងនាយករដ្ឋមន្ត្រី និងសមាជិកនៃគណៈរដ្ឋមន្ត្រី តាមរយៈការបោះឆ្នោតដកសេចក្តីទុកចិត្ត។ សភានេះ ដឹកនាំដោយប្រធានសភា ដែលធ្វើជាប្រធានសភាជាតិផងដែរ។ ប្រធានសភានេះ ត្រូវបានអមដោយអនុប្រធាន ២រូប។ ប្រធានគណបក្សដែលមានការគាំទ្រច្រើនជាងគេ ឬ សម្ព័ន្ធភាពគណបក្សមានការគាំទ្រច្រើនជាងគេត្រូវធ្វើជានាយករដ្ឋមន្ត្រី ចំនែកឯប្រធានគណបក្សដែលមានការច្រើនជាងគេដែរ ប៉ុន្តែគ្មានសមាជិកកាន់ដំណែងជានាយករដ្ឋមន្ត្រីនឹងក្លាយជាប្រធានគណបក្សប្រឆាំង។ ប្រធានគណបក្សប្រឆាំង គឺជាដំណែងដែលមានអំណាច និងឥទ្ធិពលធំធេង។ ការបោះឆ្នោតចុងក្រោយរបស់សភានេះធ្វើឡើងនៅឆ្នាំ ២០១១។

### ខ.១. សមាជិកសភា

សភាតំណាងមានសមាជិក ៥០០រូប ក្នុងនោះសមាជិក ៤០០រូប ត្រូវបានបោះឆ្នោតផ្ទាល់ពីមណ្ឌលសភានៅក្នុងប្រទេស។ សមាជិក១០០រូបទៀតត្រូវបានជ្រើសរើសដោយប្រើប្រាស់តំណាងសមាមាត្រ តាមរយៈបញ្ជីគណបក្ស។ សមាជិកសភា ត្រូវបានជ្រើសរើសពីតំបន់បោះឆ្នោតចំនួន ៨ (តំបន់មួយៗ រួមបញ្ចូលខេត្តមួយចំនួន) សមាជិក ១០រូប សម្រាប់តំបន់នីមួយៗ។ ប្រព័ន្ធនេះហៅថា សមាជិកភាគច្រើនចម្រុះ ដែលក្នុងនោះអ្នកបោះឆ្នោត ២ដង មួយសម្រាប់សមាជិកសភាតាមមណ្ឌលបោះឆ្នោត និងមួយទៀតសម្រាប់គណបក្សនៅក្នុងតំបន់បោះឆ្នោតដែលអ្នកបោះឆ្នោតរស់នៅ។

ដើម្បីមានសិទ្ធិធ្វើជាបេក្ខភាពសមាជិកសភាតំណាង ចាំបាច់ត្រូវបំពេញនូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០១ នៃរដ្ឋធម្មនុញ្ញរបស់ប្រទេសថៃ រួមមាន ៖

- មានសញ្ជាតិថៃពីកំណើត
- ត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ ឬច្រើនជាងនេះ គិតទៅដល់ថ្ងៃបោះឆ្នោតហើយ ត្រូវតែបានកើតនៅលើទឹកដីនៃមណ្ឌល ដែលខ្លួនឈរឈ្មោះសម្រាប់ការបោះឆ្នោត។
- បេក្ខជនត្រូវតែមានឈ្មោះបោះឆ្នោតនៅបញ្ជី យ៉ាងហោចណាស់ ៥ឆ្នាំ មុនការបោះឆ្នោតមកដល់ មិនត្រឹមតែប៉ុណ្ណោះ បេក្ខជនត្រូវមានលំនៅដ្ឋាន ឬ បានបំពេញការងារក្នុងវិស័យសេវាសាធារណៈនៅមណ្ឌលនោះ យ៉ាងតិចណាស់រយៈពេល ៥ឆ្នាំ។
- បេក្ខជន ត្រូវតែជាសមាជិកនៃវិទ្យាស្ថានអប់រំនៃមណ្ឌលនោះក្នុងរយៈពេល ៥ឆ្នាំ ជាបន្តបន្ទាប់។

- បេក្ខជន ត្រូវតែជាសមាជិកនៃគណបក្សនយោបាយណាមួយ ក្នុងរយៈពេលយ៉ាងហោចណាស់ ៩០ថ្ងៃ មុនដល់ថ្ងៃបោះឆ្នោត លើកលែងតែក្នុងករណីនៃការរំលាយក្នុងអំឡុងពេលអប្បបរមា ៣០ថ្ងៃ។ ការធ្វើបែបនេះ គឺក្នុងគោលដៅបញ្ឈប់ការផ្លាស់ប្តូរគណបក្សមុនការបោះឆ្នោត។
- មិនធ្លាប់ប្រកាសក្ស័យធន
- មិនត្រូវជាបុគ្គលដែលធ្លាប់ប្រព្រឹត្តអំពើពុករលួយ កេងបន្លំថវិកាជាតិ
- មិនត្រូវជាបុគ្គលធ្លាប់ញៀនថ្នាំ
- មិនត្រូវជាសមាជិករដ្ឋាភិបាល សមាជិកព្រឹទ្ធសភា និងនៅក្នុងប្រព័ន្ធតុលាការ។

### ខ.២. អាណត្តិរបស់សភាតំណាង

សភាតំណាង មានអាណត្តិ ៤ឆ្នាំ។ នៅពេលដែលសភាតំណាង អស់សុពលភាព នោះព្រះមហាក្សត្រនឹងចេញព្រះរាជក្រឹត្យសម្រាប់ការបោះឆ្នោតជាទូទៅរបស់សភា ហើយកាលបរិច្ឆេទនៃការបោះឆ្នោតត្រូវតែបានប្រកាសក្នុងអំឡុងពេល ៤០ថ្ងៃ បន្ទាប់ពីសភាអស់សុពលភាព។ សភាតំណាងនេះ អាចត្រូវបានរំលាយនៅពេលណាមួយ មុនផុតអាណត្តិ។

### ខ.៣. ភារកិច្ចរបស់សភាតំណាង

ដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញនៃប្រទេសថៃ សភាតំណាងមានភារកិច្ច ក៏ដូចជាអំណាចផ្តាច់មុខដូចខាងក្រោម ៖

- <u>ភារកិច្ចដែលត្រូវធ្វើរួមគ្នាជាមួយព្រឹទ្ធសភា</u> ៖
    - ការតាក់តែងច្បាប់
    - ការត្រួតពិនិត្យលើការតាក់តែងច្បាប់
    - អនុម័តសេចក្តីព្រាងច្បាប់
    - ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ
- <u>អំណាចផ្តាច់មុខ</u> ៖
    - ជាសភាជាន់ទាបនៃអង្គការនីតិបញ្ញត្តិ
    - បង្កើត និងតែងតាំងគណៈកម្មាការសម្រាប់ត្រួតពិនិត្យសេចក្តីព្រាងច្បាប់
    - មានសិទ្ធិក្នុងការកោះហៅរដ្ឋមន្ត្រីណាមួយ ដើម្បីមកបង្ហាញខ្លួន និងឆ្លើយតបទៅនឹងសំណួររបស់សមាជិកសភា។
    - ដកហូតដំណែងនាយករដ្ឋមន្ត្រី តាមរយៈការបោះឆ្នោតដកសេចក្តីទុកចិត្តតាមសម្លេងច្រើនជាង ១/៥ នៃការពិភាក្សាដេញដោលរបស់សមាជិកសភា។

- ដកហូតដំណែងរដ្ឋមន្ត្រី តាមសម្លេងច្រើនជាង ១/៦ នៃការពិភាក្សាដេញដោលនៃសមាជិកសភា។
- ជ្រើសរើសមន្ត្រីបម្រើការរបស់ខ្លួន
- មានសិទ្ធិក្នុងការបណ្តេញចេញសមាជិករបស់ខ្លួន
- កំណត់អំពីវិធាន និងនីតិវិធីនៃដំណើរការស្ថាប័នរបស់ខ្លួន

ខ.៤. អភ័យឯកសិទ្ធិសភា

សមាជិកសភាតំណាង មានអភ័យឯកសិទ្ធិសភា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ មិនមានសមាជិកព្រឹទ្ធសភាណាមួយត្រូវបាន ចាប់ខ្លួន ឃាត់ខ្លួន ឬ ត្រូវបានកោះហៅដោយដីកាក្នុងគោលដៅនៃការស៊ើបអង្កេត។ ក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ចាំបាច់ត្រូវតែមានការអនុញ្ញាតិពីសភាតំណាង។

## ផ្នែកទី ៣
## ការប្រៀបធៀបអង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ

បន្ទាប់ពីបានរៀបរាប់ដោយសង្ខេបអំពីសញ្ញាណទូទៅ និងដំណើរការមួយចំនួននៃអង្គការនីតិបញ្ញត្តិរបស់ប្រទេសកម្ពុជា នៅក្នុងផ្នែកនេះនឹងធ្វើការបង្ហាញអំពីភាពដូចគ្នា និងខុសគ្នារបស់ស្ថាប័នកំពូលរបស់ប្រទេសទាំងពីរនេះវិញម្តង។

**ក. ភាពដូចគ្នា និងប្រហាក់ប្រហែល**

❖ សភាជាន់ទាប

ប្រទេសទាំងពីរនេះ មានសភាជាន់ទាបដូចគ្នា ដែលប្រទេសកម្ពុជា ហៅថា រដ្ឋសភា ចំណែកឯ ប្រទេសថៃ ហៅថា សភាតំណាង។ សភាជាន់ទាបទាំងពីរ មានសិទ្ធិ និងអំណាចប្រហាក់ប្រហែលគ្នាក្នុងកម្រិតមួយខ្ពស់ ដែលរួមមានដូចខាងក្រោម ៖

- ជាសភាដែលមានអំណាច និងឥទ្ធិពល
- សមាជិកសភា ត្រូវបានជ្រើសរើសតាមការបោះឆ្នោត
- អនុវត្តប្រព័ន្ធបោះឆ្នោតសមាមាត្រ
- លក្ខខណ្ឌអាយុសម្រាប់បេក្ខភាពសមាជិកសភា ២៥ឆ្នាំ ដូចគ្នា
- កំណត់អំពីលក្ខខណ្ឌសញ្ជាតិពីកំណើតដូចគ្នាសម្រាប់សមាជិកសភា
- ជាស្ថាប័នមានសិទ្ធិ តាក់តែង អនុម័តច្បាប់ និងធ្វើវិសោធនកម្ម
- មានសិទ្ធិកោះហៅនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីនៃស្ថាប័នណាមួយមកបង្ហាញខ្លួនហើយឆ្លើយតបទៅនឹងសំនួររបស់សមាជិកសភា។

- មានសិទ្ធិក្នុងការដកហូតដំណែងនាយករដ្ឋមន្ត្រីតាមការបោះឆ្នោតដកសេចក្តីទុកចិត្តផ្អែកតាមសម្លេងរបស់សមាជិកសភា។
- កំណត់អំពីអភ័យឯកសិទ្ធិនៃសមាជិកសភា
- មានសិទ្ធិដកហូតអភ័យឯកសិទ្ធិរបស់សមាជិកសភា

❖ សភាជាន់ខ្ពស់

- មានអំណាចទាបជាងសភាតំណាង
- ការកំណត់អំពីនីតិកាលព្រឹទ្ធសភា (កម្ពុជា និងថៃ មានអាណត្តិ ៦ឆ្នាំ)
- សមាជិកព្រឹទ្ធសភាកើតចេញពីការតែងតាំងនិងការជ្រើសតាំងចេញពីការបោះឆ្នោត។
- ត្រួតពិនិត្យលើការតាក់តែងច្បាប់ និងសេចក្តីព្រាងច្បាប់
- មានភារកិច្ចសម្របសម្រួលការងារជាមួយរដ្ឋសភា ឬ សភាតំណាង
- លក្ខខណ្ឌអាយុសម្រាប់បេក្ខភាពសមាជិកព្រឹទ្ធសភា ៤០ឆ្នាំ ដូចគ្នា
- កំណត់អំពីលក្ខខណ្ឌសញ្ជាតិពីកំណើតដូចគ្នាសម្រាប់សមាជិកព្រឹទ្ធសភា
- កំណត់អំពីវិសមិតភាពជាមួយមុខងារជាសមាជិកសភាដូចគ្នា
- កំណត់អំពីអភ័យឯកសិទ្ធិនៃសមាជិកព្រឹទ្ធសភា
- មានសិទ្ធិដកហូតអភ័យឯកសិទ្ធិរបស់សមាជិកព្រឹទ្ធសភា

**ខ. ភាពខុសប្លែកគ្នា**

❖ សភាជាន់ទាប

- ចំនួនអាណត្តិសភាខុសគ្នា (រដ្ឋសភាកម្ពុជាមានអាណត្តិ ៥ឆ្នាំ រីឯ សភាតំណាងថៃមានអាណត្តិ ៤ឆ្នាំ)។
- ចំនួនសមាជិក (សមាជិកសភាកម្ពុជា ១២៣រូប , ថៃ ៥០០ រូប)
- ការកំណត់អំពីការរំលាយសភា (កម្ពុជា មិនអាចរំលាយមុនអាណត្តិបាន , ថៃ អាចរំលាយបាន)។
- ការកំណត់រយៈពេលបោះឆ្នោត បន្ទាប់ពីសភាផុតសុពលភាព (កម្ពុជា ធ្វើឡើងក្នុងរយៈពេល ៦០ថ្ងៃ យ៉ាងយូរ , ថៃ ធ្វើឡើងក្នុងរយៈពេល ៤០ថ្ងៃ)។
- សមត្ថកិច្ចកំណត់កាលបរិច្ឆេទនៃការបោះឆ្នោត (កម្ពុជា ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ , ថៃ កំណត់ និងប្រកាសដោយព្រះមហាក្សត្រ)។
- នីតិវិធីផ្សេងៗទៀតនៅក្នុងដំណើរការនៃការប្រព្រឹត្តទៅរបស់សភា។

❖ សភាជាន់ខ្ពស់

- ការធ្វើវិសោធនកម្ម (កម្ពុជា មិនមានសិទ្ធិក្នុងការធ្វើវិសោធនកម្ម ប៉ុន្តែថៃមានសិទ្ធិ)
- ការកំណត់អំពីការបន្តនីតិកាលរបស់ព្រឹទ្ធសភា (កម្ពុជា អាចបន្តបានម្តង ប៉ុន្តែថៃមិនអាចបន្តបាន)។
- ចំនួនសមាជិក (កម្ពុជា ត្រូវមានពាក់កណ្តាលនៃសមាជិករដ្ឋសភាស្មើនឹង ៦១រូប ប៉ុន្តែថៃ មានចំនួន ១៥០រូប)។

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការបង្ហាញដោយសង្ខេបអំពីសញ្ញាណនៃស្ថាប័នកំពូលអង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក៏ដូចជាការប្រៀបធៀបលើចំណុចសំខាន់ៗមួយចំនួនរបស់ស្ថាប័នកំពូលនេះ បានបញ្ជាក់ឲ្យយើងឃើញថាប្រទេសទាំងពីរនេះ ស្ថិតនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ប្រកាន់របបនយោបាយ រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដូចគ្នា មិនតែប៉ុណ្ណោះ បើយើងពិនិត្យមើលទៅលើដំណើរការនៃអង្គការនីតិបញ្ញត្តិទៀតសោត ក៏មានលក្ខណៈដូច និងប្រហាក់ប្រហែលគ្នាច្រើន។ យ៉ាងណាមិញ វាក៏មានលេចឡើងនូវភាពខុសគ្នាមួយចំនួនផងដែរ ដែលនេះអាចទាញឲ្យយើងមើលឃើញ ពីភាពដូចគ្នា ភាពខុសគ្នា ហើយធ្វើការសិក្សា និងវិភាគអំពីកំសោយភាព និងចំនុចវិជ្ជមាន នៃដំណើរការរបស់ស្ថាប័នកំពូលនៃប្រទេសទាំងពីរ។

# ឯកសារយោង


១/ ច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ
- ច្បាប់ស្តីពីការបោះឆ្នោតនៃព្រះរាជាណាចក្រកម្ពុជា

២/ សៀវភៅ

- ចំណេះដឹងអំពីអាស៊ាន រៀបរៀងដោយសាស្ត្រាចារ្យ *ស៊ិន សុយន  សិក ហេងឡុង គាត គា*
- សេចក្តីផ្តើមនីតិ រៀបរៀងដោយសាស្ត្រាចារ្យ *ប៉ូយ ធីតា*

៣/ គេហទំព័រ

- http://en.wikipedia.org/wiki/Senate_of_Thailand
- http://www.asianlii.org/th/legis/const/2007/1.html
- http://en.wikipedia.org/wiki/House_of_Representatives_(Thailand)